KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់គណនីជូនកូន

Terms and Conditions of Using Junior Account

ចោះពុម្ពលើកទី ១

មាតិកា

1. សេចក្តីផ្តើម (Introduction) 1
2. និយមន័យនៃពាក្យគន្លឹះ (Key Terms) 1
3. មធ្យោបាយក្នុងការស្នើសុំបើកគណនីជូនៀ (Requesting Channel) 2
4. ប្រភេទគណនីជូនៀ (Account Type) 2
5. ឈ្មោះគណនី (Account Name) 2
6. មធ្យោបាយក្នុងការធ្វើប្រតិបត្តិការលើគណនីជូនៀ (Transaction Channel) 2
7. រូបិយប័ណ្ណគណនី (Account Currency) 2
8. ទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា (Initial Deposit and Minimum Balance) 3
9. ទំហំទឹកប្រាក់ក្នុងគណនី និងទំហំប្រតិបត្តិការ (Account and Transaction Limit) 3
10. រយៈពេលដាក់ប្រាក់បញ្ញើ (Deposit Term) 3
11. អត្រាការប្រាក់ (Interest Rate) 3
12. ពន្ធកាត់ទុក (Withholding Tax) 3
13. ចំនួនគណនីជូនៀ (Number of Junior Account) 4
14. កម្រៃសេវា (Fee) 4
15. លក្ខខណ្ឌស្នើសុំបើកគណនីជូនៀ (Request to Open Junior Account) 4
16. ការដាក់ប្រាក់បញ្ញើ (Deposit) 5
17. ការដកប្រាក់បញ្ញើ (Withdrawal) 6
18. ការបិទគណនីជូនៀ (Junior Account Closing) 6
19. គណនីគ្មានប្រតិបត្តិការ (Dormant Account) 6
20. សិទ្ធិរបស់អាណាព្យាបាលលើការប្រើប្រាស់គណនីជូនៀ (Roles & Rights of the Parent/Guardian) 6
21. សិទ្ធិរបស់កូនលើការប្រើប្រាស់គណនីជូនៀ (Roles and Rights of the Junior) 7
22. ការស្នើសុំធ្វើបច្ចុប្បន្នកម្មគណនីជូនៀនៅពេលកុមារឈានចូលអាយុ 18ឆ្នាំ (Junior Turns to 18 Years) 8
23. ការដោះស្រាយវិវាទសម្រាប់អតិថិជន (Dispute Resolution) 8
24. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (Anti-Money Laundering and Combating Financing Terrorism) 8
25. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង (Amendment Interest Rate, Fees, Conditions and Notification) 9
26. ច្បាប់ និងការដោះស្រាយវិវាទ (Law and Dispute Resolutions) 9
27. ស្វ័យភាពនៃបញ្ញត្តិ (Severability) 9
28. ភាសា (Language) 9

1. **សេចក្តីផ្តើម** (Introduction)

លក្ខខណ្ឌនៃការប្រើប្រាស់ **គណនីជូនៀ** (Junior Account) តទៅហៅថា «លក្ខខណ្ឌប្រើប្រាស់» គឺជាកិច្ចព្រមព្រៀងរវាង លោក-លោកស្រី ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក ហៅកាត់ថា **«ខេប៊ីប្រាសាក់»** ក្នុងការប្រើប្រាស់ផលិតផលប្រាក់បញ្ញើមួយនេះ។

សូម លោក-លោកស្រី អានលក្ខខណ្ឌនេះដោយប្រុងប្រយ័ត្ន មុននឹងចុចលើប៊ូតុង **«យល់ព្រម»** ដើម្បីបន្តលើការស្នើសុំបង្កើត និងប្រើប្រាស់ **គណនីជូនៀ** តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

នៅពេល លោក-លោកស្រី បានចុចលើប៊ូតុង **«យល់ព្រម»** មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌទាំងអស់ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ និងទទួលខុសត្រូវលើការស្នើសុំបង្កើត និងប្រើប្រាស់ **គណនីជូនៀ** របស់លោក-លោកស្រី និងកូនៗរបស់ លោក-លោកស្រី តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងមធ្យោបាយផ្សេងៗទៀតដែលបានផ្តល់ដោយធនាគារ។

2. **និយមន័យនៃពាក្យគន្លឹះ** (Key Terms)

- ❖ លោក-លោកស្រី ៖ សំដៅដល់អតិថិជនដែលជាឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ដែលជាអ្នកស្នើសុំបើកគណនីជូនៀសម្រាប់កូនៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- ❖ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ៖ គឺជាកម្មវិធីធនាគារមួយដែលអនុញ្ញាតឱ្យអតិថិជនអាចទាញយកកម្មវិធីពី App Store/Play Store នៅលើទូរស័ព្ទដៃឆ្លាតវៃ និងអាចធ្វើការចុះឈ្មោះប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ លើគណនីបញ្ញើសន្សំរបស់ខ្លួនបានគ្រប់ពេលវេលា (24/7) និងគ្រប់ទីកន្លែង។
- ❖ គណនីជូនៀ ៖ គឺជាប្រភេទគណនីប្រាក់បញ្ញើសន្សំមួយប្រភេទ ដែលលោក-លោកស្រីអាចស្នើសុំបង្កើតតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile» សម្រាប់កូនៗដើម្បីឱ្យគាត់អាចធ្វើប្រតិបត្តិការគណនីជូនៀបាន តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក-លោកស្រី។
- ❖ អតិថិជនពេញលេញ ៖ ជាអតិថិជន ដែលបានផ្តល់ព័ត៌មានពេញលេញមកខេប៊ីប្រាសាក់ដោយយោងតាមវិធាននៃការយកចិត្តទុកដាក់ស្គាល់អតិថិជន (Know Your Customer)៖
  - ការទទួលបានព័ត៌មានពេញលេញពីអតិថិជន៖ ព័ត៌មានផ្ទាល់ខ្លួន លេខទំនាក់ទំនង មុខរបរ ប្រភពចំណូល។ល។
  - គោលបំណង នៃការបើកគណនី និង
  - ទទួលបានការផ្ទៀងផ្ទាត់ព័ត៌មានផ្សេងៗទៀតដោយផ្ទាល់ពីបុគ្គលិកខេប៊ីប្រាសាក់ទៅតាមលក្ខខណ្ឌតម្រូវរបស់ខេប៊ីប្រាសាក់។

❖ អតិថិជនមិនពេញលេញ ៖ អតិថិជន ដែលបានចុះឈ្មោះបើក **គណនីឌីជីថល** តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងបានបំពេញព័ត៌មានសំខាន់ៗដូចជា៖ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន លេខអត្តសញ្ញាណប័ណ្ណ លេខទូរស័ព្ទ ថតរូប សែលហ្វីថតរូបអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព និងព័ត៌មានផ្សេងៗទៀតទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ អតិថិជនប្រភេទនេះអាចធ្វើប្រតិបត្តិការប្រចាំថ្ងៃទៅតាមទំហំកំណត់ជាក់លាក់មួយ ដែលត្រូវបានកំណត់ដោយខេប៊ីប្រាសាក់ (ទំហំតូចជាងអតិថិជនប្រភេទជា Full KYC)។

3. **មធ្យោបាយក្នុងការស្នើសុំបើកគណនីជូនៀ** (Requesting Channel)

3.1. ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ អាចស្នើសុំបង្កើតគណនីជូនៀ (Submit Request) សម្រាប់កូនៗរបស់ខ្លួនបានតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile» នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

3.2. សំណើសុំបើក គណនីជូនៀ នឹងត្រូវបានបញ្ជូនទៅកាន់ធនាគារ ខេប៊ីប្រាសាក់ ដើម្បីពិនិត្យ និងអនុម័តក្នុងរយៈពេល 24 ម៉ោង នៃថ្ងៃធ្វើការ។

4. **ប្រភេទគណនីជូនៀ** (Account Type)

4.1. គណនីជូនៀ គឺជាគណនីរួម (Joint Account) រវាង កូន និងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ណាម្នាក់ដែលជាអ្នកស្នើសុំបើកគណនីជូនៀ

4.2. កូន (Junior) គឺជាម្ចាស់គណនីច្បង (Primary Account) និងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ដែលស្នើសុំបើកគណនីជូនៀ គឺជាអ្នករួមគណនី (Joint Account Holder)។

5. **ឈ្មោះគណនី** (Account Name)

- ឈ្មោះគណនី នៃ គណនីជូនៀ ត្រូវបានកំណត់យកឈ្មោះកូន (Junior) ដែលជាម្ចាស់គណនីច្បងធ្វើជាឈ្មោះគណនី (Account Name) ដោយស្វ័យប្រវត្តិ។

6. **មធ្យោបាយក្នុងការធ្វើប្រតិបត្តិការលើគណនីជូនៀ** (Transaction Channel)

- លោក-លោកស្រី និងកូន អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុនៅលើគណនីជូនៀបាន តាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile» ដោយយោងទៅតាមមុខងារនីមួយៗមានចែងនៅក្នុងសិទ្ធិនៃការប្រើប្រាស់គណនីសម្រាប់លោក-លោកស្រី និងកូន។

7. **រូបិយប័ណ្ណគណនី** (Account Currency)

7.1. នៅពេលការស្នើសុំបង្កើតគណនីជូនៀទទួលបានការអនុម័តពីធនាគារ អតិថិជននឹងទទួលបានគណនីជូនៀចំនួន 02 រូបិយប័ណ្ណដោយស្វ័យប្រវត្តិរួមមាន៖

- គណនីប្រាក់រៀល (KHR) និង
- គណនីប្រាក់ដុល្លារអាមេរិក (USD)។

7.2. ករណីអតិថិជន ឬ កុមារធ្វើប្រតិបត្តិការខុសពីរូបិយប័ណ្ណគណនី ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃជាក់ស្តែងរបស់ខេប៊ីប្រាសាក់នៅថ្ងៃធ្វើប្រតិបត្តិការនោះ។

8. **ទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា** (Initial Deposit and Minimum Balance)

- មិនតម្រូវទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា សម្រាប់ការបើក និងរក្សាទុកក្នុងគណនីជូនៀឡើយ។

9. **ទំហំទឹកប្រាក់ក្នុងគណនី និងទំហំប្រតិបត្តិការ** (Account and Transaction Limit)

9.1. ទំហំទឹកប្រាក់ក្នុងគណនីជូនៀ និងទំហំទឹកប្រាក់ប្រតិបត្តិការសម្រាប់លោក-លោកស្រី ក្នុងគណនីជូនៀតាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល គឺត្រូវបានកំណត់ដោយផ្អែកទៅតាមប្រភេទអតិថិជនដែលជា «ម្ចាស់គណនីច្បង» ជាប្រភេទ «អតិថិជនពេញលេញ/Full KYC» ឬ «អតិថិជនមិនពេញលេញ/Partial KYC» ។

9.2. ទំហំទឹកប្រាក់ប្រតិបត្តិការសម្រាប់កុមារតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ត្រូវបានកំណត់ដូចខាងក្រោម៖

- ទំហំក្នុង 01 ប្រតិបត្តិការ៖ USD 250 ឬ KHR 1,000,000
- ទំហំក្នុង 01 ថ្ងៃ៖ USD 250 ឬ KHR 1,000,000

9.3. លោក-លោកស្រី មានសិទ្ធិក្នុងការដំឡើងទំហំទឹកប្រាក់ប្រតិបត្តិការខាងលើសម្រាប់កូន រហូតដល់ USD 500 ឬ KHR 2,000,000 ។

10. **រយៈពេលដាក់ប្រាក់បញ្ញើ** (Deposit Term)

10.1. មិនមានរយៈពេលកំណត់លើការដាក់ប្រាក់បញ្ញើនៅក្នុង គណនីជូនៀ ឡើយ។

10.2. លោក-លោកស្រី អាចប្រើប្រាស់គណនីជូនៀសម្រាប់ការទូទាត់ផ្សេងៗរហូតដល់លែងមានតម្រូវការប្រើប្រាស់គណនី ឬ បិទគណនី។

11. **អត្រាការប្រាក់** (Interest Rate)

11.1. អត្រាការប្រាក់ត្រូវបានផ្តល់ជូនដោយយោងទៅតាមសមតុល្យដែលមានជាក់ស្តែងនៅក្នុងគណនី។

11.2. ការប្រាក់នឹងត្រូវបានបង្គរជាប្រចាំថ្ងៃ និងទូទាត់ចូលទៅក្នុងគណនីជូនៀ នៅរៀងរាល់ដើមខែនីមួយៗ ឬ នៅពេលបិទគណនី។

11.3. លោក-លោកស្រី អាចស្វែងរកព័ត៌មាននៃអត្រាការប្រាក់បាននៅតាមសាខាខេប៊ីប្រាសាក់ និង/ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ។

12. **ពន្ធកាត់ទុក** (Withholding Tax)

12.1. ការប្រាក់ ដែលទទួលបានពីទំហំទឹកប្រាក់នៅក្នុងគណនីនឹងត្រូវជាប់កាតព្វកិច្ចពន្ធកាត់ទុក ឬ ពន្ធផ្សេងៗតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តិជាធរមាន។

12.2. **ពន្ធកាត់ទុក** ជាបន្ទុករបស់ លោក-លោកស្រី និងយល់ព្រមឱ្យ ខេប៊ីប្រាសាក់ ទូទាត់ **ពន្ធកាត់ទុក** ចេញពីគណនីជូនៀរបស់ លោក-លោកស្រី ដោយស្វ័យប្រវត្តិនៅរៀងរាល់ពេលដែល ខេប៊ីប្រាសាក់ បានបញ្ចូលការប្រាក់ជូន លោក-លោកស្រី។

12.3. អត្រាពន្ធ៖

- **4% សម្រាប់និវាសនជន**
- **14% សម្រាប់អនិវាសនជន**

13. ចំនួនគណនីជូនៀ (Number of Junior Account)

- លោក-លោកស្រី អាចស្នើសុំបង្កើតគណនីជូនៀបាន ចំនួន 02 គណនី (KHR & USD) សម្រាប់កូនម្នាក់។

14. កម្រៃសេវា (Fee)

14.1. មិនមានកម្រៃសេវាលើការស្នើសុំបើក បិទ ឬ ធ្វើបច្ចុប្បន្នកម្មលើគណនីជូនៀឡើយ។

14.2. សម្រាប់កម្រៃសេវានៃការធ្វើប្រតិបត្តិការតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» គឺយោងទៅតាមប្រភេទប្រតិបត្តិការនីមួយៗនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ម៉ូបាល។

15. លក្ខខណ្ឌស្នើសុំបើកគណនីជូនៀ (Request to Open Junior Account)

15.1. អតិថិជនជាជនជាតិខ្មែរ និងជនបរទេស ដែលជាឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ដែលមានកូនប្រុស ឬ ស្រី អាយុចាប់ពី 10ឆ្នាំ ដល់ក្រោម 18ឆ្នាំ អាចស្នើសុំបង្កើតគណនីជូនៀបានដោយខ្លួនឯង នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile»។

15.2. លក្ខខណ្ឌតម្រូវសម្រាប់ លោក-លោកស្រី ដែលជាឪពុកម្តាយ ឬ អាណាព្យាបាល៖

1. ជាជនជាតិខ្មែរ ឬ ជនបរទេស
2. ជាអតិថិជនដែលមានគណនីនៅខេប៊ីប្រាសាក់ស្រាប់ (អាចជាអតិថិជនពេញលេញ-Full KYC ឬ មិនពេញលេញ-Partial KYC)
3. មានប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
4. ស្នើសុំបង្កើតគណនីសម្រាប់កូនដែលស្ថិតនៅក្រោមសិទ្ធិនៃការគ្រប់គ្រងស្របច្បាប់របស់ខ្លួន
5. មានឯកសារគ្រប់គ្រាន់បញ្ជាក់ពីទំនាក់ទំនងរវាងកូន និងអាណាព្យាបាលស្របច្បាប់
6. យល់ព្រម និងទទួលខុសត្រូវទាំងស្រុងលើការប្រើប្រាស់គណនី និងការធ្វើប្រតិបត្តិការលើគណនីដោយកូនរបស់លោក-លោកស្រី និងត្រូវធានាថា កូនរបស់លោក-លោកស្រី មិនប្រើប្រាស់គណនីដើម្បីធ្វើប្រតិបត្តិការទាំងឡាយណាដែលល្មើសច្បាប់ណាមួយក្នុងប្រទេសកម្ពុជា ឬ ច្បាប់អន្តរជាតិ។

15.3. លោក-លោកស្រី ត្រូវបំពេញព័ត៌មានរបស់កូន សម្រាប់ការស្នើសុំបង្កើតគណនីជូនៀ នៅក្នុង «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile» រួមមាន៖

- ឈ្មោះពេញ
- ថ្ងៃខែឆ្នាំកំណើត
- ភេទ
- សញ្ជាតិ
- ថតរូបកូន

- ថតរូបឯកសារបញ្ជាក់អត្តសញ្ញាណរបស់កូន និង
- ថតរូបឯកសារបញ្ជាក់អំពីទំនាក់ទំនងរវាងកូន និងឪពុក/ម្តាយ/អាណាព្យាបាលស្របច្បាប់ (តម្រូវក្នុងករណីឯកសារបញ្ជាក់អត្តសញ្ញាណរបស់កូនមិនមានបញ្ជាក់ទំនាក់ទំនងរវាងកូន និងអាណាព្យាបាល ដូចជា ឯកសារបញ្ជាក់អត្តសញ្ញាណ ឬ លិខិតឆ្លងដែន ជាដើម)។ល។

15.4. លក្ខខណ្ឌតម្រូវសម្រាប់កូនៗរបស់លោក-លោកស្រី៖

1. មានអាយុចាប់ពី 10ឆ្នាំ ទៅ តូចជាង 18ឆ្នាំ
2. មានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវ និងមានសុពលភាព
3. មានឯកសារបញ្ជាក់ពីទំនាក់ទំនងរវាងកូន និងអាណាព្យាបាលស្របច្បាប់
4. មានប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ និងលេខទូរស័ព្ទផ្ទាល់ខ្លួន ដើម្បីអាចទាញយកកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ពី App Store / Play Store ដើម្បីប្រើប្រាស់គណនីជូនៀដែលស្នើសុំបង្កើតដោយលោក-លោកស្រី
5. មានចំណេះដឹងគ្រប់គ្រាន់ក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល និងការការពារហានិភ័យផ្សេងៗ។

15.5. ឯកសារតម្រូវសម្រាប់បញ្ជាក់អត្តសញ្ញាណរបស់កុមារ ដែលត្រូវបញ្ចូលទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលរួមមាន៖

- សំបុត្រកំណើត / សំបុត្របញ្ជាក់កំណើត ឬ
- សៀវភៅគ្រួសារ ឬ
- សៀវភៅស្នាក់នៅ ឬ
- លិខិតឆ្លងដែន
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង
- ឯកសារពាក់ព័ន្ធ ដែលបញ្ជាក់ពីទំនាក់ទំនង មាតាបិតា ឬ អាណាព្យាបាល។

15.6. បន្ទាប់ពីលោក-លោកស្រី បានបំពេញព័ត៌មានរួចរាល់ សំណើស្នើសុំបើកគណនីជូនៀ នឹងត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិមកកាន់ ធនាគារ ខេប៊ីប្រាសាក់ ដើម្បីពិនិត្យ និងអនុម័ត មុនលោក-លោកស្រី អាចបន្តទៅបើកឱ្យដំណើរការ (Activate) គណនីជូនៀសម្រាប់កូនៗនៅលើទូរស័ព្ទដៃរបស់ពួកគេ។

16. ការដាក់ប្រាក់បញ្ញើ (Deposit)

ការដាក់ប្រាក់ចូលទៅក្នុងគណនីជូនៀ អាចធ្វើឡើងតាមមធ្យោបាយណាមួយខាងក្រោម៖

- នៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ
- ផ្ទេរចូលតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ
- ផ្ទេរចូលតាមរយៈសេវាខេប៊ីប្រាសាក់ឧបភោគ ឬ
- ម៉ាស៊ីនដាក់ប្រាក់ ឬ
- ទទួលការផ្ទេរប្រាក់ចូលពីធនាគារផ្សេង (ក្នុងប្រទេស ឬ ក្រៅប្រទេស)។ល។

17. **ការដកប្រាក់បញ្ញើ** (Withdrawal)

17.1. កូនរបស់លោក-លោកស្រី អាចដកជាសាច់ប្រាក់ចេញពីគណនីជូនៀបានដោយ៖

- ប្រើមុខងារ «ផ្ទេរប្រាក់តាមលេខកូដសម្ងាត់ (Cash-Code)» នៅលើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដើម្បីទទួលបានលេខកូដ 06 ខ្ទង់ ក្នុងការដកប្រាក់តាមម៉ាស៊ីនអេធីអឹម របស់ខេប៊ីប្រាសាក់ ឬ
- ធ្វើប្រតិបត្តិការស្កេន QR ដកប្រាក់ តាមម៉ាស៊ីនអេធីអឹមរបស់ខេប៊ីប្រាសាក់ ដើម្បីដកជាសាច់ប្រាក់។

17.2. លោក-លោកស្រី អាចស្នើសុំដកជាសាច់ប្រាក់ចេញពីគណនីជូនៀបាននៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ដោយត្រូវអនុលោមទៅតាមនីតិវិធីកំណត់ដោយខេប៊ីប្រាសាក់។

18. **ការបិទគណនីជូនៀ** (Junior Account Closing)

- លោក-លោកស្រី អាចស្នើសុំបិទគណនីជូនៀ ជាលាយលក្ខណ៍អក្សរបាននៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់។

19. **គណនីគ្មានប្រតិបត្តិការ** (Dormant Account)

19.1. គណនីជូនៀ ដែលមិនមានប្រតិបត្តិការក្នុងរយៈពេលចាប់ពី 365 ថ្ងៃ ឡើងទៅ នឹងក្លាយទៅជាគណនីគ្មានប្រតិបត្តិការ។

19.2. លោក-លោកស្រី យល់ព្រមឱ្យខេប៊ីប្រាសាក់ធ្វើការទូទាត់កម្រៃសេវា គណនីគ្មានប្រតិបត្តិការជាប្រចាំខែ ដោយកម្រៃសេវានឹងត្រូវបានទូទាត់ចេញពីគណនីជូនៀដោយស្វ័យប្រវត្តិ។

19.3. គណនីជូនៀដែលមិនមានប្រតិបត្តិការរយៈពេល 10 ឆ្នាំជាប់គ្នា ខេប៊ីប្រាសាក់នឹងធ្វើការផ្ទេរសមតុល្យគណនីជូនៀទៅធនាគារជាតិ នៃ កម្ពុជា ដើម្បីគ្រប់គ្រងបន្តដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

19.4. លោក-លោកស្រី អាចធ្វើការបើកឱ្យដំណើរការគណនីជូនៀដែលគ្មានប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ស្នើសុំនៅតាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត។

20. **សិទ្ធិរបស់អាណាព្យាបាលលើការប្រើប្រាស់គណនីជូនៀ** (Roles & Rights of the Parent/Guardian)

20.1. អាណាព្យាបាល មានសិទ្ធិប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាលដើម្បីស្នើសុំបង្កើត និងគ្រប់គ្រងលើគណនីជូនៀ ដូចខាងក្រោម៖

1. ស្នើសុំបង្កើតគណនីជូនៀសម្រាប់កូនៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
2. មានសិទ្ធិប្រើប្រាស់មុខងារ «ផ្ទេរប្រាក់ចេញពីគណនីជូនៀ ទៅ គណនីផ្ទាល់ខ្លួន/Own Account Transfer» តែប៉ុណ្ណោះ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
3. ពិនិត្យសមតុល្យ និងទាញយករបាយការណ៍គណនី
4. បង្ហាញ KHQR Code និងចែករំលែកទៅអ្នកដទៃ ជារូបភាព KHQR និង Deep link សម្រាប់ទូទាត់
5. អាចបង្ខាំង ឬ ដោះបង្ខាំង លើសិទ្ធិប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល របស់កូនៗបានគ្រប់ពេល
6. អាច Link ឬ Delink គណនីជូនៀចេញពី Account List របស់ខ្លួន ដោយមិនប៉ះពាល់ដល់ការប្រើប្រាស់គណនីជូនៀនៅលើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលរបស់កូនឡើយ

7. អាចដំឡើង ឬ បន្ថយទំហំទឹកប្រាក់ប្រើប្រាស់ប្រចាំថ្ងៃ (Daily Limit) និង/ឬ ទំហំទឹកប្រាក់ប្រតិបត្តិការ (Transaction Limit) សម្រាប់កូនលើការប្រើប្រាស់គណនីជូនៀតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល
8. មិនអាចកំណត់យកគណនីជូនៀជាគណនីគោល (Default Account) សម្រាប់ការប្រើប្រាស់ KHQR លើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលរបស់ខ្លួនឡើយ។

20.2. មានសិទ្ធិស្នើសុំធ្វើគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុលើគណនីជូនៀ ដូច គណនីសន្សំទូទៅ បន្ទាប់ពីអាណាព្យាបាលបានស្នើសុំធ្វើបច្ចុប្បន្នកម្ម ដោយបញ្ចូលគំរូហត្ថលេខា (Specimen) លើ គណនីជូនៀ រួចរាល់នៅតាមសាខា។

20.3. ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ មានកាតព្វកិច្ច និងទទួលខុសត្រូវទាំងស្រុងក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់គណនីជូនៀ និងសោធនាគារទាំងឡាយដែលពាក់ព័ន្ធដោយអនីតិជន។

20.4. ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់ប្រតិបត្តិការ កាតព្វកិច្ច កម្រៃសេវា ការខាតបង់ ការទទួលខុសត្រូវ និងផលវិបាកទាំងឡាយ ដែលកើតឡើង ឬ ពាក់ព័ន្ធនឹងការប្រើប្រាស់គណនីជូនៀលើការធ្វើប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ប័ណ្ណនិម្មិតវីសា ឬ ផ្សេងៗ។

21. សិទ្ធិរបស់កូនលើការប្រើប្រាស់គណនីជូនៀ (Roles and Rights of the Junior)

21.1. កូនមានសិទ្ធិក្នុងការប្រើប្រាស់គណនីជូនៀ បានតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលជាមួយមុខងារ (Available Functions) ដែលបានអនុញ្ញាតដូចខាងក្រោម៖

1. បើកឱ្យដំណើរការ (Activate) គណនីជូនៀ នៅលើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដែលបានស្នើសុំបង្កើតដោយអាណាព្យាបាលរបស់ខ្លួន
2. ពិនិត្យសមតុល្យ និងទាញយករបាយការណ៍គណនី
3. បង្ហាញ KHQR Code និងចែករំលែកទៅអ្នកដទៃ ជារូបភាព KHQR និង Deep link សម្រាប់ទូទាត់
4. ផ្ទេរប្រាក់ពីគណនីជូនៀ ទៅ គណនីជូនៀ ផ្ទាល់ខ្លួន
5. ផ្ទេរប្រាក់ពីគណនីជូនៀ ទៅ គណនីផ្សេងនៅខេប៊ីប្រាសាក់ ឬ ឆ្លងធនាគារ ឬ គណនី Wallet
6. ផ្ទេរប្រាក់តាមលេខកូដសម្ងាត់
7. បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ
8. ទូទាត់វិក្កយបត្រ
9. ស្កេនដើម្បីទូទាត់ជាមួយ KHQR របស់ខេប៊ីប្រាសាក់ ឬ ធនាគារផ្សេង
10. ស្កេន QR ដើម្បីដាក់ប្រាក់តាមម៉ាស៊ីនដាក់ប្រាក់ (CDM)
11. ស្កេន QR ដើម្បីដកប្រាក់តាមម៉ាស៊ីនអេធីអឹម (ATM)
12. បើកគណនីបញ្ញើមានកាលកំណត់ (ត្រឹមកម្រិតនៃទំហំទឹកប្រាក់សម្រាប់អតិថិជន)
13. បង្កើត Template / Schedule
14. បង្កើតប័ណ្ណនិម្មិត (Virtual Card) ចំនួន01 ប័ណ្ណ និងទំហំកំណត់ក្នុងមួយប័ណ្ណត្រឹម USD 100 និងអាចប្រើប្រាស់ និងគ្រប់គ្រងប័ណ្ណនិម្មិតបានគ្រប់ប្រភេទតាមលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ។

21.2. ប្រភេទប្រតិបត្តិការដែលកូន មិនអាចធ្វើបានតាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (Restriction Functions) និងបញ្ជរបេឡា រួមមាន៖

1. ស្នើសុំកម្ចី
2. ផ្ទេរប្រាក់អន្តរជាតិ
3. មិនអាចបង្កើតគណនីបន្ថែម ដូចជា គណនីសន្សំ គណនីចម្រើនគ្មានកាលកំណត់ គណនីចម្រើនតាមលំដាប់ គណនីឌីជីថល និងគណនីក្រុម។ល។
4. មិនអាចស្នើសុំប័ណ្ណឥណពន្ធគ្រប់ប្រភេទ ដែលជាប្រភេទប័ណ្ណផ្លាស្ទិក
5. មិនអាចបង្វាំងគណនីជូនៀ
6. មិនអាច Delink គណនីជូនៀចេញពី Account List របស់ខ្លួន
7. មិនអាចធ្វើគ្រប់ប្រភេទប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុនៅតាមបញ្ជរបេឡា (Counter) នៃធនាគារខេប៊ីប្រាសាក់។

22. **ការស្នើសុំធ្វើបច្ចុប្បន្នកម្មគណនីជូនៀនៅពេលកុមារឈានចូលអាយុ 18ឆ្នាំ** (Junior Turns to 18 Years)

- នៅពេលកុមារឈានចូលដល់អាយុ18 ឆ្នាំ មាតាបិតា ឬ អាណាព្យាបាល និង កុមារ អាចអញ្ជើញទៅកាន់សាខាខេប៊ីប្រាសាក់ណាមួយ ដើម្បីស្នើសុំធ្វើបច្ចុប្បន្នកម្ម ដើម្បីឱ្យកូនអាចមានលទ្ធភាពក្នុងការប្រើប្រាស់គណនី និងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានពេញលេញ (Full Access) ដូចអតិថិជនទូទៅ។

23. **ការដោះស្រាយវិវាទសម្រាប់អតិថិជន** (Dispute Resolution)

23.1. លោក-លោកស្រី អាចស្នើសុំដោះស្រាយវិវាទ ឬ កែតម្រូវប្រតិបត្តិការ ដែលខ្លួនបានបញ្ជាពីគណនីជូនៀតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយផ្សេងៗ ជាលាយលក្ខណ៍អក្សរ ឬ តាមរយៈមន្ត្រីទំនាក់ទំនងអតិថិជន (Call Center)។

23.2. ខេប៊ីប្រាសាក់ នឹងពិនិត្យ និងដោះស្រាយវិវាទឱ្យបានសមស្របទៅតាមនីតិវិធី។

24. **ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** (Anti-Money Laundering and Combating Financing Terrorism)

- អនុលោមតាមបទប្បញ្ញត្តិទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លោក-លោកស្រីទទួលស្គាល់ និងយល់ព្រមថា ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល បង្វាំងគណនី ឬ បង្វាំងសមតុល្យគណនីរបស់លោក-លោកស្រី ឬ មិនធ្វើប្រតិបត្តិការជូនលោក-លោកស្រីបាន ប្រសិនបើ ខេប៊ីប្រាសាក់មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖
  - ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះគោលបំណងនៃការបើកគណនី
  - ប្រតិបត្តិការ ឬ គណនីរបស់លោក-លោកស្រី មានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
  - មានការបង្គាប់បញ្ជាពីអាជ្ញាធរមានសមត្ថកិច្ច ដូចជា តុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា ជាដើម។

25. **ការកែប្រែអត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង** (Amendment Interest Rate, Fees, Conditions and Notification)

25.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា និងលក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់គណនីរបស់ លោក-លោកស្រី និងកូនរបស់លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅលោក-លោកស្រី ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

25.2. ក្នុងរយៈពេលនៃការជូនដំណឹង ករណីមិនមានការតវ៉ាពីលោក-លោកស្រី ត្រូវសន្មតថាអតិថិជនបានយល់ព្រម និងទទួលយកការកែប្រែខាងលើមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមាន ដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1) តាមរយៈសាខារបស់ខេប៊ីប្រាសាក់ និង/ឬ
2) តាមរយៈវេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3) ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4) តាមរយៈការផ្សព្វផ្សាយនៅលើទំព័រកាសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយផ្សេងៗ ដែល ខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

25.3. លោក-លោកស្រី ត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពី ខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួន តាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

26. **ច្បាប់ និងការដោះស្រាយវិវាទ** (Law and Dispute Resolutions)

26.1. លក្ខខណ្ឌទូទៅនេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា។

26.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា។

26.3. បញ្ហាផ្សេងៗ ដែលមិនមានចែងនៅក្នុងប្រការទាំងនេះ ត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

26.4. រាល់លក្ខខណ្ឌផ្សេងៗ ដែលមិនមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះ ត្រូវអនុវត្តដោយយោងទៅតាម **«លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់»** ដែល លោក-លោកស្រី អាចស្វែងរកបាននៅតាមវេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ឬ តាមសាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិត លោក-លោកស្រី បំផុត។

27. **ស្វ័យភាពនៃបញ្ញត្តិ** (Severability)

- ប្រសិនបើប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

28. **ភាសា** (Language)

- លក្ខខណ្ឌនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕